# ការផ្តល់រទេះជនពិការ

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានផ្តល់រទេះជនពិការឲ្យទៅ អ្នកពិការចំនួន៣នាក់ :

១. ឈ្មោះ សំ ភឿនច័ន្ទ ភេទ ស្រី អាយុ ៥៨ ឆ្នាំ រស់នៅភូមិ ទី៥ សង្កាត់ ខ្សាម ក្រុង កំពង់ឆ្នាំង ខេត្ត កំពង់ឆ្នាំង ។ គាត់ឈឺសន្លាក់ដៃជើង អស់រយៈពេល១៤ឆ្នាំមកហើយ ដើរមិនរួចដោយសារដុះឆ្អឹងពករឹងតាមសន្លាក់ជើងធ្វើឲ្យគាត់បត់ដោយពិបាកបំផុត ។ គាត់ជាសមាជិកពួកជំនុំសេចក្តីមេត្តាករុណានៃព្រះគ្រីស្ទកំពង់ឆ្នាំង ។





លោក ទូច ប៊ុនសឿម
ជាតំណាងឲ្យអង្គការCMC
បានផ្តល់រទេះជនពិការឲ្យទៅអ្នកពិការ



លោកគ្រូគង្វាល
សំ ច័ន្ទរិទ្ធី



២. ឈ្មោះ កោះ ខុន ភេទ ស្រី អាយុ ៧៣ ឆ្នាំ រស់នៅសង្កាត់ ផ្សារដេប៉ូ៣ ខណ្ឌ ទួលគោក ក្រុង ភ្នំពេញ ។ គាត់បាក់ឆ្អឹងត្រគាក ដើរមិនរួច ។ គាត់ជាសមាជិកនៃពួកជំនុំព្រះជាម្ចាស់ (AOG) ។

លោកគ្រូគង្វាល
ទឹក ស្រ៊ីន

៣. ឈ្មោះ ជ័យ រ័ត្ន ភេទ ប្រុស អាយុ ១៩ ឆ្នាំ រស់នៅ ភូមិ ប្រាំបីមុំ ឃុំ ប្រាំបីមុំ ស្រុក ត្រាំង ខេត្ត តាកែវ ។ គាត់មានជម្ងឺ មេរោគស៊ីសាច់ដុំ ។ ជាសមាជិកពួកជំនុំព្រះជាម្ចាស់ ខេត្តតាកែវ (AOG) ។





លោក ទូច ប៊ុនសឿម
ជាតំណាងអង្គការCMC បានចុះទៅផ្តល់រទេះ
ជនពិការដល់សាលារៀនតែម្តង ។

នាយិការ
សាលា

ម្តាយអ្នកពិការជាស្រ្តីមេម៉ាយ ។ ប្តីគាត់រត់
ចោលចាប់ពីដឹងថាកូនទាំងពីរនេះពិការ





ប្អូនប្រុសបង្កើត
របស់អ្នកពិការ គាត់ក៏ពិការដែរ ។ ឥឡូវនេះ
អង្គការមិនទាន់មានរទេះឲ្យគាត់នៅឡើយទេ
ពីព្រោះអង្គការបានផ្តល់ឲ្យទៅអ្នកមុនអស់ហើយ
ជម្ងឺរបស់គេគឺដូចបងគេអីចឹងដែរ
មេរោគស៊ីសាច់ដុំអស់ ធ្វើឲ្យគេដើរមិនរួចៗ

ពួកគេទាំងពីរនាក់ លើកដៃសំពះអរគុណ
ចំពោះសប្បុរសជនទាំងអស់ដែលបានផ្តល់
រទេះនេះដល់គេ ដើម្បីប្រើប្រាស់និងធ្វើដំណើរ

ខ្ញុំបាទជាតំណាងឲ្យអង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះអស់លោក លោកស្រី ដែលបានផ្តល់ រទេះជនពិការទាំងនេះ មកឲ្យជនពិការនៅក្នុងប្រទេសកម្ពុជា ដែលកំពុងតែជួបប្រទះការខ្វះខាត និងភាពក្រីក្រ ។
សូមព្រះជាម្ចាស់ប្រទានពរដល់លោកអ្នកបងប្អូនទាំងអស់ ឲ្យបានប្រកបតែសេចក្តីសុខចំរើនៗ

ភ្នំពេញ, ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០

អំពីខ្ញុំ ទូច ប៊ុនសឿម